ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងពាណិជ្ជកម្ម**
**អគ្គនាយកដ្ឋានពាណិជ្ជកម្មអន្តរជាតិ**
**នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ**
លេខៈ១៨៤....សបអ

## សូមគោរពជូន
## ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងពាណិជ្ជកម្ម

តាមរយៈ ៈ ឯកឧត្តមអគ្គនាយកពាណិជ្ជកម្មអន្តរជាតិ និង ឯកឧត្តមរដ្ឋលេខាធិការ

កម្មវត្ថុ ៈ របាយការណ៍ស្តីពីកិច្ចប្រជុំគណៈកម្មការអនុវត្តន៍ (IC) លើកទី២០

ភ្ជាប់ជូន ៈ របៀបវារៈនៃកិច្ចប្រជុំ, បញ្ជីវត្តមាន និងបទបង្ហាញ

ឆ្នាំពីរពាន់ដប់ពីរ ខែមិថុនា ថ្ងៃទីប្រាំមួយ នៅក្រសួងពាណិជ្ជកម្មបានបើកកិច្ចប្រជុំនៃគណៈកម្មការអនុវត្តន៍ (IC) លើកទី២០ ក្រោមអធិបតីភាព ឯកឧត្តម ប៉ាន សូរស័ក្តិ រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម និងជាប្រធានគណៈកម្មការអនុវត្តន៍ (IC) ដោយមានសមាជិក-សមាជិកាមកពីក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធចូលរួមដូចមានក្នុងបញ្ជីវត្តមានជាឧបសម្ព័ន្ធ ១។
របៀបវារៈកិច្ចប្រជុំ (ឧបសម្ព័ន្ធ ២) និង ចំណុចសំខាន់ៗដែលបានពិភាក្សារួមមានៈ

- របាយការណ៍វឌ្ឍនភាពរបស់គម្រោង TDSP ( ថវិកា–Benchmarks ឆ្នាំ២០១២ ) ។
- ការកែសម្រួលថវិការបស់គម្រោង Export Training– SME Training និង គម្រោង Value Chain Information Unit របស់នាយកដ្ឋានជំរុញពាណិជ្ជកម្ម និងការពិភាក្សាលើបទបង្ហាញ គម្រោងយុទ្ធសាស្ត្រថ្មីស្តីអំពី ASYCUDA World System របស់អគ្គនាយកដ្ឋានគយ–រដ្ឋាករ

បន្ទាប់ពីលោក ឈៀង ពេជ្រ ប្រធាននាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិបានរាយការណ៍អំពីវឌ្ឍនភាពរបស់គម្រោង TDSP តាមរយៈបទបង្ហាញដូចមានភ្ជាប់ជាឧបសម្ព័ន្ធ ៣ រួចមក និងអមដោយបទបង្ហាញរបស់តំណាង នាយកដ្ឋានជំរុញពាណិជ្ជកម្ម និង អគ្គនាយកដ្ឋានគយ–រដ្ឋាករជូនអង្គប្រជុំ អង្គប្រជុំបានពិភាក្សាយ៉ាងលំអិត លើហេតុផល ការបង្កើនថវិកាគម្រោង Export Training – SME Training និង Value Chain Information Unit របស់នាយកដ្ឋានជំរុញពាណិជ្ជកម្ម និងការពិភាក្សាពង្រាងគម្រោងយុទ្ធសាស្ត្រថ្មីស្តីអំពី ASYCUDA World System អគ្គនាយកដ្ឋានគយ – រដ្ឋាករ ដែលកន្លងមកបានទទួលថវិការពីគម្រោង TFCP។ កំណត់ហេតុពិស្តារមានភ្ជាប់ជាឧបសម្ព័ន្ធ ៤ ។ ជូសមុខគណៈកម្មាការអនុវត្តន៍គម្រោង (IC) ឯកឧត្តម ប៉ាន សូរស័ក្តិ បានធ្វើការបូកសរុបជាលទ្ធផលរួម និងផ្តល់អនុសាសន៍ដូច ខាងក្រោមៈ

- អនុម័តទៅលើការកែប្រែបន្ថែមថវិកាចំនួន 5,300 USD សម្រាប់គម្រោង Export Training – SME Training របស់នាយកដ្ឋានជំរុញពាណិជ្ជកម្ម ។
- យល់ព្រមជាគោលការណ៍អំពីការកែសម្រួលថវិកាគម្រោង Value Chain Information Unit ដោយមានលក្ខខណ្ឌដោយតម្រូវឲ្យក្រុម M&E របស់ DICO ចុះទៅធ្វើ ការត្រួតពិនិត្យ និង

របស់អគ្គនាយកដ្ឋានគយ និង រដ្ឋាករ ដោយមាន [illegible] GDCE-WB ធ្វើការពិភាក្សាលក្ខណៈបច្ចេកទេសស៊ីជម្រៅអំពី សកម្មភាពការងារ-ថវិការ សមស្របតាមនីតិវិធី Trade SWAp/TDSP រួចហើយធ្វើ របាយការណ៍ដាក់មក គណៈកម្មាការអនុវត្តន៍គម្រោង (IC) និង បន្ទាប់មកដាក់ជូន SSC ស្របតាមនីតិវិធីដំណើរការវាយ តម្លៃជ្រើសរើសគម្រោងនៃ TDSP។ ដោយមិនរង់ចាំកិច្ចប្រជុំ ពេញអង្គរបស់ SSC និងជាមួយការយល់ព្រមរបស់សមាជិក SSC នានាតាមរយៈសារអេឡិចត្រូនិច ឯកឧត្តម ទេសរដ្ឋមន្ត្រី ជាប្រធាន SSC នឹងពិនិត្យ-សម្រេចចុងក្រោយ ។

- ចំពោះថវិការ TDSP នៅសល់សម្រាប់គម្រោងថ្មីដទៃ គណៈកម្មាការអនុវត្តន៍ គម្រោង (IC) បានណែនាំមានការរៀបចំប្រជុំ ក្រុមការងាររបស់សរសរស្តម្ភទាំងបី ដើម្បីជម្រាបជូនឲ្យបានដឹងមុន ដើម្បីសសរស្តមនីមួយៗ អាចសម្រាំងយកគម្រោងយុទ្ធសាស្ត្ររបស់ខ្លួនមកស្នើរសុំថវិការដែលនៅសល់សម្រាប់អនុវត្ត។

កិច្ចប្រជុំបានបញ្ចប់នៅវេលាម៉ោង ១២:០០ ក្នុងបរិយាកាសរីករាយ និងប្រកបដោយលទ្ធផលល្អ ។ អាស្រ័យដូចបានជម្រាបជូនខាងលើ សូមឯកឧត្តម មេត្តាជ្រាបជារបាយការណ៍ ។

សូម ឯកឧត្តម ទេសរដ្ឋមន្ត្រី មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ អំពីខ្ញុំបាទ ។

រាជធានីភ្នំពេញ, ថ្ងៃទី 08 ខែ មិថុនា ឆ្នាំ២០១២

អ្នកធ្វើរបាយការណ៍

ហង់ សុជីវិន

លេខាធិការ

ចម្លងជូន:

- ឯ.ឧ ប្រធាន - អនុប្រធាន និងសមាជិកគណៈកម្មការអនុវត្តគម្រោង
- ឯ.ឧ លោក - លោកស្រី ប្រធានក្រុមការងារសសរស្តម្ភទី១ ទី២ និងទី៣

គោរពជូន **ឯកឧត្តមរដ្ឋលេខាធិការ**

ដើម្បីសុំការឯកភាពគោរពបញ្ជូនជូន **ឯកឧត្តមទេសរដ្ឋមន្ត្រី** ជ្រាប

08/06/2012

**សុខ សុភ័ក្ត្រ**

សមាជិកអចិន្ត្រៃយ៍ គណៈកម្មាការអនុវត្តគម្រោង

បានឃើញ និង ឯកភាព

គោរពបញ្ជូនជូន **ឯកឧត្តមទេសរដ្ឋមន្ត្រី**

**ប៉ាន សូរស័ក្តិ**

ប្រធានគណៈកម្មាការអនុវត្តគម្រោង